# ពាក្យពោលសរសើរលោកអ្នកសម្តែងធម៌

បពិត្រព្រះគុណចេះឆ្លាតឆ្លៀស ធម៌ណាចង្អៀតចេះកែខៃ
វែកញែកឱ្យច្បាស់អស់សង្ស័យ បញ្ញាទន់ខ្ចីគង់ស្តាប់បាន ។
ពិរោះសាច់ធម៌ដ៏ប្លែកៗ ពិរោះពន់ពេកគ្រប់សន្តាន
ទោះបីអ្នកល្ងង់គង់ភ្ញាក់ប្រាណ ដោយបានរសធម៌ផ្អែមប្រៀបគ្មាន ។
កាលណោះសម្តេចព្រះភគវា ទេសនាធម្មាប្រោសប្រទាន
ព្រះធម៌នាំសត្វទៅនិព្វាន រាប់ម៉ឺនសែនលានស្មើរគ្មានសល់ ។
កាលណោះសម័យព្រះភគវា ទេសនាធម្មាប្រទានផ្ទាល់
ព្រះអង្គប្រោសសត្វសព្វសកល លុះបានមគ្គផលច្រើនណាស់ណា ។
ឥតពីសម្តេចព្រះភគវន្ត កន្លងរាប់ពាន់ឆ្នាំហើយណា
នៅតែសាវ័កព្រះភគវា ទេសនាធម្មាពិរោះក្រៃ ។
មិនគឺសាវ័កអង្គឯណា គឺព្រះករុណាទេសន៍ថ្មីៗ
បញ្ចប់ឯវិសង្ខេបខ្លី ខ្ញុំកូណាតាយាយស្តាយណាស់ណា ។
មិនទាន់អស់ចិត្តនឹងរសធម៌ នឹងឃាត់អង្វរមិនហ៊ានថា
ឃើញនឿយព្រះកាយព្រះករុណា សូមសាធុការចប់សេចក្តី ។
ហត្ថាខ្ញុំទាំងគូផ្គង់ប្រណម លើកឡើងបង្គំគុណកែវបី
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃថ្លៃ សូមបានសេរីដូចប្រាថ្នា ។
ខ្ញុំសូមខមាទោសទាំងឡាយ ក្រែងឆ្គងដោយកាយ ឬ វាចា
នៅមានគ្រោតគ្រាតក្នុងធម៌ណា ដូចមានគាថាសូត្រក្រោយហោង ។

By: Dejkun Wat Kraya
Wat Kraya, Kraya Commune, Santuk District,
Kampong Thom Province, Camodia,
E-mail: watkraya@gmail.com
Website: http://krayayouth.wordpress.com
Phone: (+855) 62 690 5008